**ការយល់អំពីជម្ងឺខ្វះឈាម (Learn the Sign of Anemia) They include fatigue and skin paleness**
**WUML date: 3/19/06**

ជម្ងឺខ្វះះឈាមដែលហៅថា Anemia ជាជម្ងឺឈាមម្យ៉ាង ដែលអាចមាន នៅពេលណាដែល ឈាមក្រហមមានកំរិតឬចំនួនតិចខុសធម្មតា។

កោសិកាឈាមក្រហម មានជាតិ hemoglobin ដែលដឹកនាំផ្តល់ជាតិអុកស៊ីហ្សែន ទៅផ្នែកដទៃទៀតនៃរាងកាយ។ អង្គការ Nemours Foundation យល់ថា ប្រសិនបើ លោកអ្នកពុំព្យាបាលវាទេ ជម្ងឺនេះអាចមានផលវិបាកដល់រាងកាយលោកអ្នក។

មូលហេតុដែលបណ្តាលឲ្យមានជម្ងឺនេះ អាចមានច្រើន រួមទាំងការមានតពូជ, ការទទួលទានអាហារដែលពុំសូវមានជីវជាតិគ្រប់គ្រាន់, ការមានជម្ងឺអ្វីមួយ, ឬ ការប៉ះពាល់ ឬពុលជាតិនឹងថ្នាំអ្វីមួយ។

វិធីព្យាបាល គឺអាស្រ័យទៅលើមូលហេតុនិងប្រភេទនៃជម្ងឺខ្វះឈាមនីមួយៗ។ នេះ គឺមាន រួមទាំងការទទួលទានថ្នាំវិតាមិន និងថ្នាំដែលមានជាតិ អៃរោន (Iron) ផងដែរ។

អាការៈរោគនៃជម្ងឺខ្វះឈាម អាចមានពីការមានស្បែកពណ៌ស្លេកស្លាំងនិងអស់កំឡាំងល្ហិតល្ហៃ ទៅការវិលមុខនិងធឹងធោង។ ដោយសារលក្ខណៈនេះ អាចជាអាការៈរោគនៃជម្ងឺដទៃទៀត ដែរនោះ ជាការមួយចាំបាច់ លោកអ្នកគួរអញ្ជើញទៅពិភាក្សាជាមួយគ្រូពេទ្យឲ្យបានដឹងច្បាស់ ប្រសិនបើ លោកអ្នក សង្ស័យថា ខ្លួនមានជម្ងឺខ្វះឈាមនេះ។

ចំពោះពត៌មានបន្ថែម សូមមេត្តាទាក់ទងទៅគ្រូពេទ្យប្រចាំគ្រួសាររបស់លោកអ្នកឬ មណ្ឌលមេត្តាសុខភាពនៃមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែលដែលមានទូរស័ព្ទលេខ (978) 441-1700។

http://www.healthfinder.gov/news/newsstory.asp?Docid=531327